ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ចំណុះក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៩១៣ / ៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១៖** ត្រូវបានបង្កើត **អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម** ចំណុះក្រសួងមហាផ្ទៃ ។

**មាត្រា២៖** អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានតួនាទីធ្វើជាសេនាធិការជូន ក្រសួងមហាផ្ទៃ ក្នុងការដឹកនាំគ្រប់គ្រង ការងារស្ថិតិប្រជាពលរដ្ឋ ការងារផ្តល់លិខិតអត្រានុកូលដ្ឋាន ការងារផ្តល់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ការងារផ្តល់លិខិតឆ្លងដែន និងការងារផ្តល់សញ្ជាតិខ្មែរតាមលក្ខខណ្ឌនៃច្បាប់កំណត់។

**មាត្រា ៣៖** អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដឹកនាំដោយ អគ្គនាយក ០១រូប និងមាន អគ្គនាយករង មួយចំនួនជាជំនួយតាមការចាំបាច់ ។

**មាត្រា ៤៖** ត្រូវបានផ្ទេរ នាយកដ្ឋាននគរបាលស្ថិតិនិងលិខិតឆ្លងដែន ចេញពីអគ្គស្នងការដ្ឋាននគរបាលជាតិ និងផ្ទេរការងារអត្រានុកូលដ្ឋាន ការងារសញ្ជាតិ ពីអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន មកចំណុះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ។

**មាត្រា ៥៖** អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម មានរចនាសម្ព័ន្ធ ដូចតទៅ

១- នាយកដ្ឋានរដ្ឋបាលសរុប

២- នាយកដ្ឋានអគ្រានុកូលដ្ឋាន

៣- នាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ

៤- នាយកដ្ឋានលិខិតឆ្លងដែន

៥- នាយកដ្ឋានសញ្ជាតិ

**មាត្រា ៦៖** តួនាទីភារកិច្ចរបស់ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម និង តួនាទីភារកិច្ចរបស់ នាយកដ្ឋាន ចំណុះត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

**មាត្រា ៧** ៖បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែ មករា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ